**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យព្រះយេស៊ូប្រសូតជាមួយបុគ្គលិកការិយាល័យនៅភ្នំពេញថ្មី**
**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧**
***យើងទៅជាឧបករណ៍នៃសេចក្ដីសង្ឃឹម***

អត្ថបទទី១៖ អស ៧,១០-១៤
ដំណឹងល្អ៖ លក ១,២៦-៣៨

បងប្អូនជាទីស្រឡាញ់!

មួយអាទិត្យមុនយើងគោរពព្រះយេស៊ូប្រសូត ព្រះសហគមន៍បានឲ្យយើងស្ដាប់គម្ពីរដំណឹងល្អ ដែលស្ដីអំពីបងប្អូនរបស់ព្រះយេស៊ូ។ យើងបានស្ដាប់អំពីលោក សាការី ដែលបានទទួលដំណឹងមួយយ៉ាងពិសេសថា គាត់នឹងទទួលកូន ទោះបីគាត់ចាស់ណាស់ហើយ យាយអេលីសាប៉ែតជាស្រីអានិងចាស់។ នៅពេលនោះលោក សាការី គាត់ពិបាកទទួល ដូច្នេះគាត់បានទៅជាមនុស្សគ និយាយមិនកើត រហូតដល់ថ្ងៃលោកយ៉ូហានកើត។ យើងបានស្ដាប់អំពីរឿង លោកយ៉ូសែប ដែលបានសម្រេចចិត្តនៅក្នុងចិត្តរបស់គាត់យ៉ាងស្ងាត់ **"ខ្ញុំមិនអាចទទួលនាងម៉ារីជាប្រពន្ធខ្ញុំ ដោយសារគាត់មានផ្ទៃពោះ ទាំងអត់ទាន់រៀបការ"** ប៉ុន្តែទេវទូតបានបំភ្លឺគាត់ គាត់បានយល់ថានេះជាការអស្ចារ្យរបស់ព្រះជាម្ចាស់ និងគាត់បានទទួលព្រះនាងម៉ារី។ ថ្ងៃនេះយើងស្ដាប់អំពីព្រះនាងម៉ារីផ្ទាល់ ព្រះនាងម៉ារីដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីធ្វើជាម្ដាយរបស់ព្រះអង្គ និងព្រះនាងម៉ារីដែលបានទទួលដំណឹងល្អនៅក្នុងអំណរសប្បាយរបស់គាត់ ធ្វើឲ្យគាត់ពោរពេញដោយសេចក្ដីសុខរួមជាមួយព្រះជាម្ចាស់។

នៅពេលយើងមើលលោក សាការី នៅពេលយើងមើលលោក យ៉ូសែប នៅពេលយើងមើល ព្រះនាងម៉ារី ព្រះជាម្ចាស់បានជ្រើសរើសមនុស្សសុចរឹត។ ព្រះគម្ពីរបាននិយាយថាសាការីនិងអេលីសាប៉ែត ជាមនុស្សសុចរឹត លោកយ៉ូសែបជាមនុស្សសុចរឹត។ ព្រះនាងម៉ារីទោះបីមិនសរសេរ ប៉ុន្តែយើងយល់ហើយព្រះនាងម៉ារីជាស្ត្រីសុចរឹតដល់កំពូល។ ខ្ញុំជឿថាសម្រាប់យើងថ្ងៃនេះ ព្រះជាម្ចាស់ជ្រើសរើសយើងដែរ។ យើងទាំងអស់ យើងទទួលការត្រាស់ហៅមួយយ៉ាងពិសេស គឺធ្វើជាមនុស្សសុចរឹតដែលមានចិត្តស្មោះចំពោះ ព្រះជាម្ចាស់ និងព្រះសហគមន៍ និងមានចិត្តស្មោះចំពោះគ្នាទៅវិញទៅមក ដើម្បីបង្កើតទំនាក់ទំនងនៅក្នុងសេចក្ដីសុខនិងអំណរសប្បាយ។

នៅក្នុងគម្ពីរ គឺព្រះនាងម៉ារីពោរពេញដោយអំណរសប្បាយ តាមពិតសាការីនៅពេលគាត់ពិបាកជឿ ប៉ុន្តែនៅពេលគាត់បានឃើញកូនរបស់គាត់ ពេលនោះលោកសាការីនិយាយមិនកើត គាត់បានសរសេរដាក់ឈ្មោះ "**យ៉ូហាន**" ក្រោយមកគាត់អាចនិយាយបាន នៅពេលនោះគាត់ពោរពេញដោយអំណរសប្បាយ ដោយសារព្រះជាម្ចាស់បានប្រទានកូនមួយឲ្យលោក។ យ៉ូសែប ក៏ដូចគ្នាគាត់ពោរពេញដោយអំណរសប្បាយ ដោយសារគាត់មានប្រពន្ធមួយដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីមានកូនព្រះយេស៊ូ។ ហេតុនេះហើយ ព្រះជាម្ចាស់ជ្រើសរើសយើងឲ្យទៅជាមនុស្សសុចរឹត។

ព្រះជាម្ចាស់ មានគោលដៅមួយយ៉ាងពិសេសសម្រាប់យើងរៀងរៀងៗខ្លួន ឲ្យយើងពោរពេញដោយអំណរសប្បាយ។ ព្រះគម្ពីរ គឺព្រះគម្ពីរដំណឹងល្អ រាល់ដងពេលយើងស្ដាប់គម្ពីរគឺដំណឹងល្អ ដែលណែនាំឲ្យយើងរំភើប ណែនាំឲ្យយើងមានសេចក្ដីសុខ។ បន្តិចទៀត ព្រះនាងម៉ារីទៅជួបជាមួយយាយអេលីសាប៉ែត នៅពេលព្រះនាងម៉ារីគាត់ទៅដល់ព្រះនាងម៉ារីបាននិយាយមួយម៉ាត់ "**សូមជម្រាបសួរ**" នៅពេលនោះកូនរបស់យាយអេលីសាប៉ែតបានបម្រះឡើងនៅក្នុងផ្ទៃពោះរបស់គាត់ ដោយសារទាំងយ៉ូហានបាទីស្ដ ទាំងយាយអេលីសាប៉ែត និងព្រះនាងម៉ារីសប្បាយចិត្ត ដោយសារព្រះយេស៊ូនិងព្រះជាម្ចាស់ណែនាំឲ្យយើងពោរពេញដោយអំណរសប្បាយ។ កុំឲ្យយើងយល់ថា ពេលយើងស្ដាម់គម្ពីរទុកត្រឹមជាអត្ថបទមួយដែលយើងធ្លាប់ស្ដាប់ ជាអត្ថបទមួយដែលយើងថាដដែលៗ ប៉ុន្តែឲ្យយើងទទួលថាជាដំណឹងល្អ ដែលណែនាំឲ្យជីវិតរបស់យើងរកឃើញអត្ថន័យថ្មី ណែនាំឲ្យជីវិតរបស់យើងរកឃើញសេចក្ដីសង្ឃឹម។

រដូវបុណ្យព្រះយេស៊ូប្រសូត ជាពេលវេលាមួយយ៉ាងពិសេស ដើម្បីចែករំលែកសេចក្ដីសង្ឃឹម។ ខ្ញុំបានចូលទៅធ្វើបុណ្យព្រះយេស៊ូប្រសូត នៅមន្ទីរឃុំឃាំងកំពត នៅមណ្ឌលនិស្សិត ជាមួយគ្រួសារក្រីក្រនៅផ្ទះបងស្រីមេត្តាករុណា នៅសន្តប៉ូល នៅសន្តហ្វ្រង់ស្វ័រ នៅភូមិសុខសាន្តជាមួយក្មេងពិការ អ្នកមានជំងឺអេដស៍ និងប្រជាជន នៅសាលាមេត្តេយ្យ មានបុណ្យព្រះយេស៊ូប្រសូតច្រើនណាស់។ មនុស្សខុសៗគ្នា មានអ្នកក្រីក្រផង មានអ្នកជំងឺផង មានអ្នកពិការផង មានអ្នកជាប់មន្ទីរឃុំឃាំងផង មាននិស្សិតផង មានសិស្សសាលាផង មានកូនមត្តេយ្យផង...។ ប៉ុន្តែនេះ ទាំងអស់យើងមានគោលបំណងតែមួយនៅក្នុងជីវិតរបស់យើង ទោះបីយើងជាក្មេងក៏ដោយ ជាមនុស្សចាស់ក៏ដោយ យើងជាប់ឃុំឃាំង

ក៏ដោយ យើងជានិស្សិតក៏ដោយ គឺឲ្យជីវិតរបស់យើងពោរពេញដោយសេចក្តីសង្ឃឹម ឲ្យជីវិតរបស់យើងប្រកបដោយសេចក្តីសង្ឃឹម។ មនុស្សយើងពេលអស់សេចក្តីសង្ឃឹម អស់កម្លាំងហើយ មនុស្សយើងពេលអស់សេចក្តីសង្ឃឹមមិនអាចទៅមុខបានទេ។

យើងជាគ្រីស្តបរិស័ទ យើងត្រូវតែមានសេចក្តីសង្ឃឹមមួយពិសេស ដោយសារយើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង និងណែនាំឲ្យយើងទទួលអំណរសប្បាយ។ ជីវិតរបស់យើងធ្វើយ៉ាងម៉េចដើម្បីណែនាំដំណឹងល្អពិតៗ ដល់មនុស្សយ៉ាងច្រើននៅក្នុងសង្គមរបស់យើង។ ខ្ញុំជឿថាឆ្នាំ២០១៨ ជាឆ្នាំមួយយ៉ាងពិសេសសម្រាប់ប្រទេសកម្ពុជាយើង ធ្វើម៉េចដើម្បីឲ្យសេចក្តីសង្ឃឹមកើតជារូបរាងពិតៗ? ធ្វើយ៉ាងម៉េចដើម្បីឲ្យមនុស្សទាំងអស់រកឃើញយុត្តិធម៌នៅក្នុងជីវិតរបស់គេ? ធ្វើយ៉ាងម៉ែចដើម្បីឲ្យមនុស្សតូចតាចអាចដើរបានដើម្បីរកឃើញពន្លឺនៅក្នុងជីវិតផ្ទាល់ខ្លួន? **យ៉ូហានបាទីស្តបង្ហាញផ្លូវដើម្បីឲ្យរកឃើញពន្លឺ** យើងមានតួនាទីបង្ហាញពន្លឺឲ្យគេ។ ប៉ុន្តែដើម្បីបង្ហាញពន្លឺឲ្យគេ យើងត្រូវការរកឃើញពន្លឺនៅក្នុងខ្លួនយើងសិន។ ប្រសិនបើយើងអត់រកឃើញពន្លឺនៅក្នុងជីវិត យើងធ្វើដូចម្តេចដើម្បីបង្ហាញពន្លឺឲ្យគេមើលឃើញដំណើរផ្លូវសម្រាប់ជីវិតរបស់គេ? យើងត្រូវការរកឃើញពន្លឺនៅក្នុងខ្លួនយើងសិន ដើម្បីបង្ហាញពន្លឺដល់គេនៅពេលនោះ**យើងទៅជាឧបករណ៍នៃការសង្គ្រោះ ឧបករណ៍នៃសេចក្តីសង្ឃឹម**សម្រាប់បងប្អូនឯទៀតៗ។ នេះជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ និងការិយាល័យនីមួយៗទៅជាឧបករណ៍យ៉ាងពិសេស ដើម្បីណែនាំឲ្យមានអំណរសប្បាយផង សេចក្តីសង្ឃឹមផង កម្លាំងកាយកម្លាំងចិត្តរបស់ព្រះជាម្ចាស់ ទៅគ្រប់ទីកន្លែងនៅក្នុងជីវិត និងសង្គមរបស់យើង។

**កុំឲ្យយើងធ្វើជាឧបសគ្គនៃការសង្គ្រោះ តែផ្ទុយទៅវិញឲ្យយើងធ្វើជាឧបករណ៍នៃការសង្គ្រោះ** ដើម្បីណែនាំឲ្យការសង្គ្រោះទៅគ្រប់ទីកន្លែង ណែនាំឲ្យអំណរសប្បាយដែលយើងមានពីមួយថ្ងៃទៅមួយថ្ងៃ ទោះបីយើងមានឧបសគ្គ ទោះបីយើងមានទុក្ខលំបាក ទោះបីយើងមានបញ្ហា ប៉ុន្តែយើងមានអំណរសប្បាយដែរ។ ប៉ុន្មានថ្ងៃមុនខ្ញុំបានចូលរួមជាមួយកម្មករកម្មការីនៅអង្គការពន្លឺមិត្តភាព ពេលយើងស្តាប់សាក្ខីភាពនៃគ្រួសារក្រីក្រ ដែលមានទុក្ខលំបាកនៅក្នុងជីវិតពួកគេ ដែលមានបញ្ហាច្រើននៅក្នុងជីវិតរបស់គេ ក៏ប៉ុន្តែគេបានជួបជាមួយគ្រីស្តបរិស័ទម្នាក់ គេបានជួបជាមួយបងស្រីដុនបូស្កូម្នាក់ គេបានជួបជាមួយមនុស្សម្នាក់ ដែលណែនាំឲ្យជីវិតរបស់គេដែលបាត់បង់សេចក្តីសង្ឃឹមអស់រលីង គេអាចរកឃើញ

ពន្លឺសារជាថ្មី។ ការិយាល័យនីមួយៗ យើងមានឱកាសយ៉ាងពិសេសដើម្បីអនុវត្តព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានន័យថាដើម្បីនាំដំណឹងល្អនៅគ្រប់ទីកន្លែង ឲ្យមនុស្សខ្វាក់មើលឃើញ ឲ្យមនុស្សពិការដើរបាន ឲ្យអ្នកក្រីក្រទទួលដំណឹងល្អ និងឲ្យមនុស្សជាប់ឃុំឃាំងរកឃើញសេរីភាព។ សំខាន់ឲ្យយើងភ្ជាប់ជាមួយព្រះយេស៊ូ ដោយអធិដ្ឋាន ដោយស្រឡាញ់ និងដោយបម្រើជានិច្ច។

យើងសូមអរព្រះគុណព្រះអង្គ និងសូមព្រះអង្គបំភ្លឺយើងដើម្បីឲ្យជីវិតរបស់យើងភ្ជាប់នឹងព្រះអង្គជានិច្ច ដើម្បីឆ្លើយតាមព្រះនាងម៉ារី "**ខ្ញុំជាអ្នកបម្រើរបស់ព្រះម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ**"។ អាម៉ែន៕